នៅគ្រប់ដំណាក់កាលនៃអាយុ កូនលោកអ្នករៀនពីការពិសោធន៍ដែលលោកអ្នកបានផ្តល់ឲ្យ។ ជាមាតាបិតា លោកអ្នកគឺជាគ្រូបង្រៀនទីដំបូងនិងដ៏សំខាន់របស់កូន។ អ្វីៗដែលលោកអ្នកធ្វើរាល់ថ្ងៃជាមួយកូននឹងជួយគេឲ្យរៀនជំនាញដែលត្រៀមបំរុងពួកគេសម្រាប់ទៅរៀន។ កូនសៀវភៅនេះគឺបង្កើតឡើងសំរាប់ជាធនធានមួយដើម្បីជួយកូនលោកអ្នកឲ្យមានភាពរួចរាល់សម្រាប់ចូលរៀនថ្នាក់មត្តេយ្យដ្ឋាន!

សហសាលារៀនតំបន់ឡុងប៊ីច

*បណ្តុះគ្រាប់ឆ្ពោះទៅភាពរួចរាល់សម្រាប់មហាវិទ្យាល័យនិងអាជីព□*

**កូនសៀវភៅនេះបានបង្កើតឡើងដោយគណកម្មាធិការអចិន្ត្រៃយ៍ P-3 របស់ LBUSD**

*Claire Alvarez*
*Kathleen Brown*
*Teresa Cooper*
*Kristina Damon*
*Terry Dawson*
*Miriam Garcia*
*Nancy Hayashida*
*Nicole Jackson*
*Whitney Leathers*
*Blanca Litzinger*
*Melinda Mendez*
*Yvette Streeter, Chairperson*
*and members of the Long Beach ECE Committee*
*Claudia Sosa-Valderrama*
*Cynthia Young*
*Dr. Jill Baker, Founding Chairperson*

*The LBUSD P-3 Steering Committee would like to thank all Early Childhood Educators who participated in the 2014 Spring Forums. The ideas and feedback generated in these forums contributed to the development of this document. Our communities will benefit by having students prepared to enter kindergarten.*

# ភាពត្រៀមជាស្រេចសំរាប់សាលាមត្តេយ្យ

## *ការណែនាំផាលំផាប់លំដោយសម្រាប់មាតាបិតា*



សហសាលារៀនតំបន់ឡុងប៊ីច LBUSD

# ការលូតលាស់រាងកាយ





ក្មេងៗរៀនឆាប់ចេះដោយធ្វើផ្ទាល់ដៃ។ ការលេងជួយគាំទ្រដល់ការលូតលាស់ខួរក្បាលកុមារហើយជារបៀបសំខាន់សម្រាប់ឲ្យស្វែងយល់និងដឹងអំពីជីវិតជាក់ស្តែង

## លំនឹង

- លំនឹងឈរជើងមួយលារដៃទាំងពីរត្រដាង
- ទ្រថង់គ្រាប់សណ្តែកនៅលើក្បាលបួនប្រាំវិនាទី
- ដើរនៅលើគែមប្រអប់ដីខ្សាច់
- ពេលស្តាប់ចម្រៀង "Head and Shoulders, Knees and Toes" ទប់ខ្លួនឲ្យនឹងនៅពេលដែលខំអោនយកម្រាមដៃឲ្យប៉ះនឹងម្រាមជើង
- អោន ពត់ខ្លួន កាច់ចង្កេះហើយបង្វិលខ្លួនដោយមិនឲ្យបាត់លំនឹង

## ការលេង

- ហក់លោត លោតជើងមួយ និងរត់។ សាកលោតជើងទាំងពីរ លោតជើងមួយ ហើយរត់កាច់ចុះកាច់ឡើង
- អង្គុយលើបាល់ធំ
- ជិះរទេះកង់បី

## ជំនាញប្រើដៃឬជើង

- រមៀល ទះ ទាត់ និងចាប់បាល់
- បោះវត្ថុអ្វីមួយឲ្យចូលកញ្ច្រែងចម្ងាយប្រាំមួយហ្វីទពីខ្លួន
- លេខជាមួយដីឥដ្ឋ
- កាត់ជាមួយកន្ត្រៃឬហែកក្រដាស
- កឹបឡេវ រូតខ្សែរូតបិទ រូតខ្សែរូតបើក បើកឡេវ បិទឡេវ

ជំនាញធ្វើចលនាគឺជាគ្រឹះសម្រាប់ការរៀនសូត្រ។ អាយុសំរាប់បណ្តុះបណ្តាលជំនាញមានភាពខុសគ្នាពីក្មេងមួយទៅក្មេងមួយ។





## គណិតសាស្ត្រ

កុមារដែលមានឱកាសលេងជាមួយវត្ថុផ្សេងៗដែលមានរូបរាង ដុំជ័រប្លូនជ្រុងតូចៗ និងដុំរៀបចូលគ្នាតម្លើងជារូប ហើយហាត់រាប់លេខ សម្រាប់ឲ្យមានភាពរួចរាល់ស្រេចពេលចូលរៀនហើយ ពេលដែលគ្រូបង្រៀនពីគណិតសាស្ត្រ។

- រកទិញដុំជ័រឬឈើរាងបួនជ្រុងសម្រាប់ឲ្យកូនលេងរៀបតម្លើងជារូបរាងផ្សេងៗ
- រកទិញបន្ទះផ្ទាំងរូបសម្រាប់ឲ្យកូនលេងរៀបបញ្ចូលគ្នាចេញជារូបភាពឬរូបរាង។
- ជួយកូនឲ្យស្គាល់លេខដែលឃើញនៅជុំវិញខ្លួនជារាងរាល់ថ្ងៃ ដូចជាម៉ោង ថ្ងៃខែ លេខទំព័រសៀវភៅ លេខទូរស័ព្ទ អាស័យដ្ឋាន និងទំហំខោអាវជាដើម។
- រៀបគ្រោងយប់ណាមួយប្រចាំសប្ដាហ៍សម្រាប់លេងល្បែងជាគ្រួសារ ដែលមានការរាប់ ដូចជាលេងដូមីណូ បៀ ឬលេងរ៉ែក ជាដើម។
- ហាត់រាប់ពេលឃើញអ្វីៗជាទូទៅ ដូចជាចំនួនមនុស្សនៅក្នុងឡាន ចំនួនជំហ៊ានពីកន្លែងកំពុងឈរទៅឡាន ចំនួនកាំជណ្ដើរដែលកំពុងឡើង ឬចំនួននំជាដើម។
- ហាត់រៀនរាប់ចំនួនវត្ថុឬរបស់អ្វីមួយទៅវិញទៅមក វត្ថុមួយសម្រាប់ពាក្យលេខមួយ។
- រៀនធ្វើការប្រៀបធៀបឬវាស់( (ខ្ពស់ជាង-ខ្លីជាង វែងជាង-ខ្លីជាង ធ្ងន់ជាង-ស្រាលជាង ធំជាង-តូចជាង)




មាតាបិតាជាទីមេត្រី

តួនាទីរបស់លោកអ្នកជា"គ្រូបង្រៀនទីដំបូង"មានសារៈសំខានបំផុត។ សូមចងចាំឲ្យច្បាស់ថាពាក្យសរសើរ ការញញឹមដាក់កូនពេលកូនមកពីរៀនវិញ ហើយនិងការយកចិត្តទុកដាក់ទៅលើកិច្ចការដែលកូនរៀននៅសាលា មានឥទ្ធិពលជាខ្លាំងទៅលើកូន។

មិនថាឡើយលោកអ្នកមានកូនចូលរៀនសាលាមត្តេយ្យជាលើកដំបូងឬធ្លាប់មានកូនទៅរៀនចូលសាលារួចមកហើយក៏ដោយ គ្មានអ្វីសំខាន់ជាងឆ្នាំដំបូងនេះទេ។ ឆ្នាំសាលាមត្តេយ្យពោរពេញទៅដោយការលូតលាស់រាងកាយ លូតលាស់ផ្នែកធ្វើទំនាក់ទំនងគ្នា ហើយនិងការលូតលាស់ចំណេះវិជ្ជា។ ខណៈដែលលោកអ្នកជួយគាំទ្រកូននៅក្នុងដំណាក់កាលនៃការលូតលាស់នេះ គឺកូនលោកអ្នករំពឹងទៅលើលោកអ្នក ដើម្បីភាពកក់ក្ដៅ និងទំនុកចិត្ត ហើយកត្តាទាំងពីរនេះហើយដែលនឹងជួយបំប៉ននៅក្នុងការអប់រំចិញ្ចឹមកូនរបស់លោកអ្នក។

ខណៈដែលលោកអ្នកអានកូនសៀវភៅនេះ យើងសង្ឃឹមថាលោកអ្នកនឹងប្រើយោបល់ផ្សេងៗនៅក្នុងកូនសៀវភៅនេះដើម្បីជួយកូនលោកអ្នកឲ្យបណ្ដុះភាពមានទំនុកចិត្តលើខ្លួនឯង ហើយនឹងដឹងថាអ្វីខ្លះនឹងកើតមានឡើងនៅសាលាមត្តេយ្យ។

យើងរង់ចាំទទួលគ្រួសារលោកអ្នកមកចូលរួមជាចំណែកគ្រួសាររបស់ LBUSD!

Dr. Jill A. Baker
ភូឈួយអគ្គនាយកសាលារៀន

# រៀបចំត្រៀមឲ្យស្រេចសម្រាប់សាលាមត្តេយ្យ

**ការចូលសាលាមត្តេយ្យគឺជាពេលផ្លាស់ប្តូរមួយសម្រាប់កុមារនិងមាតាបិតា។ កុមារខ្លះមិនចង់ទៅកន្លែងណាថ្មីជួបមនុស្សដែលមិនធ្លាប់ស្គាល់ទេ។ ខាងក្រោមនេះគឺជារបៀបខ្លះៗដើម្បីធ្វើឲ្យឆ្នាំសាលាមត្តេយ្យដំបូងមានភាពរលូនល្អសម្រាប់លោកអ្នកនិងកូន។**

- នាំកូនទៅពិធីណែនាំពីសាលាមត្តេយ្យ Kindergarten Festival ដើម្បីឲ្យបានដឹងអំពីរបៀបចុះឈ្មោះចូលរៀននិងជំនាញផ្សេងៗសម្រាប់ត្រៀមខ្លួនផ្ទេរពីសាលាបឋមមត្តេយ្យទៅសាលាមត្តេយ្យ។
- នាំកូនទៅពិធីណែនាំពីការសិក្សានិងសាលារៀន Education Celebration ដែលមានធ្វើឡើងក្នុងខែមករាជារៀងរាល់ឆ្នាំដើម្បីឲ្យបានដឹងអំពីកម្មវិធីសិក្សាផ្សេងៗនៅតាមសាលាបឋមសិក្សា។
- ចូលទៅវែបសាយ lbschools.net/schoolfinder ឬទូរស័ព្ទទៅលេខ 562-997-8247 ដើម្បីឲ្យដឹងសាលារៀនណាដែលឋិតនៅក្នុងតំបន់លំនៅដ្ឋានរបស់លោកអ្នក។
- ទូរស័ព្ទទៅសាលាក្នុងតំបន់លំនៅដ្ឋានរបស់លោកអ្នកដើម្បីឲ្យបានដឹងថ្ងៃខែនិងម៉ោងនៃកម្មវិធីណែនាំពីសាលានិងជួបគ្រូ Open House ហើយនិងនាំកូនទៅជាមួយផង។
- ទូរស័ព្ទទៅសាលាក្នុងតំបន់លំនៅដ្ឋានរបស់លោកឬចូលទៅវែបសាយសាលាដើម្បីឲ្យបានដឹងអំពី: -ថ្ងៃខែចុះឈ្មោះចូលរៀន -ឯកសារដែលចាំបាច់ -ការទៅមើលសាលាជាមួយកូនលោកអ្នក
- អានសៀវភៅជាមួយកូនអំពីការចូលរៀនសាលាមត្តេយ្យដំបូង ដូចជាសៀវភៅខាងក្រោមនេះ:
  - *Miss Bindergarten Gets Ready for Kindergarten* by Joseph Slate
  - *The First Day Jitters* by Julie Danneberg
  - *Lookout Kindergarten, Here I Come* by Nancy Carlson
- មុនចាប់ផ្តើមចូលសាលាហាត់ធ្វើទម្លាប់ពេលព្រឹកដើម្បឲ្យធ្លាប់
- បង្រៀនកូនឲ្យចេះបើកប្រអប់អាហារថ្ងៃត្រង់
- សរសេរតារាងវេលារបស់កូនដោយប្រើពាក្យនិងរូប។ បើកូនត្រូវទៅកន្លែងគេមើលថែពេលចេញពីរៀន ដាក់ព័ត៌មាននោះផងដែរ
- នៅថ្ងៃចូលរៀនដំបូង សរសេរកូនក្រដាសមួយហើយដាក់ក្នុងប្រអប់អាហារឬសំពាយរបស់កូនដែលផ្តាំកូនថាម៉ាក់ឬប៉ានឹងចាំជួបកូនក្រោយពេលចេញពីរៀន
- កុំភ្លេចថតរូបទុកជាអនុស្សាវរីយ៍រំលឹកថ្ងៃពិសេសរបស់កូន




## ការអាន

**កុមារដែលត្រូវបានអានឲ្យស្តាប់ជារៀងរាល់ថ្ងៃចេះពាក្យស្តាប់បាននិងពាក្យនិយាយក៏ច្រើនដែរ**

- រៀបចំធ្នើរដែលមានសៀវភៅសម្រាប់ឲ្យកូនអាន
- រកពេលណាមួយប្រចាំថ្ងៃសម្រាប់អានឲ្យកូនស្តាប់ដើម្បីបណ្តុះចំណូលចិត្តអាន
- អានសៀវភៅផ្សេងៗដែលមានចំណាប់អារម្មណ៍ខ្លាំង(សៀវភៅរឿង សៀវភៅពីព្រឹត្តិការណ៍ពិតៗ និងកំណាព្យជាដើម)
- ពេលអាន និយាយជជែកគ្នាអំពីរូបភាពនៅក្នុងសៀវភៅជាមួយកូន
- អូសម្រៀមដៃក្រោមពាក្យនៅពេលកំពុងអានឲ្យកូនស្តាប់ដើម្បីឲ្យកូនយល់ពីអក្សរដែលគេបោះពុម្ព
- ទុកឲ្យកូនបើកទំព័រខ្លួនឯង
- សួរសំណួរងាយៗ(អ្នកណា អ្វី ឯណា ពេលណា ហេតុអ្វី)អំពីរឿងហើយឲ្យកូនទាយថានឹងមានអ្វីកើតឡើងបន្ទាប់មកទៀត
- នាំកូនទៅរកសៀវភៅអាននៅបណ្ណាល័យ

## ការសរសេរ

**កុមារដែលមានឱកាសលេងជាមួយសម្ភារៈសរសេរនឹងបង្កើតជំនាញប្រើម្រាមដៃដែលចាំបាចសម្រាប់សរសេរ**

- មានសម្ភារៈសម្រាប់សរសេរ ដូចជាក្រដាស ខ្មៅដៃ ក្រេយ៉ុងពណ៌ ប៊ិចពណ៌ជាដើមសម្រាប់ឲ្យកូនសរសេរនិងគូររូបលេង
- បង្រៀនកូនឲ្យចេះសរសេរឈ្មោះដោយប្រើអក្សរធំជាមួយអក្សរទីដំបូងនៃឈ្មោះ ហើយប្រើអក្សរតូចទាំងអស់បន្ទាប់មក
- ប្រើប៊ិចបំភ្លឺដើម្បីសរសេរឈ្មោះកូន រូបរាង អក្សរ លេខ ហើយប្រាប់ឲ្យកូនសរសេរតាមដានពីលើ





# ការអាន និង ការសរសេរ

## អក្សរ សម្លេង ពាក្យចួន

**កុមារដែលបណ្តុះការចេះដឹងនៃអក្សរ សម្លេង និងពាក្យចួន នឹងមានការងាយស្រួលច្រើន ពេលរៀនអាននិងរៀនសរសេរនៅសាលា**

- ពេលបង្រៀនកូនអំពីអក្សរលើកដំបូង ចាប់ផ្តើមជាមួយអក្សរក្នុងឈ្មោះរបស់កូន
- រកមើលជាមួយកូននូវអក្សរដែលកូនស្គាល់នៅពេលអាន
- ប្រើអក្សរជំរដែលមានដែកឆក់សម្រាប់រៀបសរសេរឈ្មោះកូន
- អានសៀវភៅ ABC ជាមួយកូន
- ច្រៀងបទតួរអក្សរ Alphabet Song ជាមួយកូន
- ច្រៀងបទសាមញ្ញសម្រាប់ក្មេងដែលមានពាក្យចួនគ្នាជាមួយកូន
- ធ្វើពាក្យឲ្យចួនគ្នាដោយប្តូរសម្លេងដើមពាក្យ(ដូរសម្លេងនៅដើមពាក្យ hat ទៅ ជាពាក្យចួននឹង cat, rat, និង bat ជាដើម



# ជោគជ័យនៅសាលាមត្តេយ្យ

ឆ្នាំដំបូងនៃការទៅរៀនអាចជាការរំភើបមួយហើយក៏អាចជាការពិបាកមួយដែរ។ ត្រូវចងចាំថាធ្វើយ៉ាងណាឲ្យមានតុល្យភាពក្នុងជីវិតកូនតូចរបស់លោកអ្នក។ នៅសាលានឹងមានអ្វីៗថ្មីជាច្រើនសម្រាប់កូនលោកអ្នកត្រូវរៀនចងចាំ។

## បណ្តុះបណ្តាលចំណង់ដឹងរបស់កូន

- នាំគ្នាដើរលេងនៅជិតផ្ទះ ហើយនិយាយគ្នាអំពីអ្វីៗដែលមើលឃើញនៅតាមផ្លូវ
- សួរសំណួរដែលមានចម្លើយត្រូវច្រើនលើសពី១ (ឧ. “តើកូនគិតថាអ្វីនឹងកើតឡើងបើ...?” “តើកូនគិតទៅមើលថាហេតុដូចម្តេចបានជាវាកើតឡើងអញ្ចឹង?”
- ជួយរកចម្លើយទៅនឹងចំងល់ដែលកូនមាន
- ប្រាប់កូនឲ្យដឹងអំពីចំណូលចិត្តនិងទំលាប់របស់លោកអ្នក

## ជួយកូនឲ្យចេះមានរបៀបរាបរយហើយឲ្យមានសុខភាពល្អ

- ទុកពេលឲ្យគ្រប់គ្រាន់ដើម្បីឲ្យកូនរៀបចំខ្លួនទៅរៀនពេលព្រឹកដើម្បីឲ្យកូនទៅរៀនដោយមានអារម្មណ៏ល្អហើយឲ្យបានទទួលជោគជ័យល្អនៅសាលា
- រៀបចំសម្ភារៈទុកជាមុនឲ្យរួចស្រេចពីយប់
- ជួយឆែកមើលសំពាយឲ្យមានរបៀបរាបរយដោយឆែកមើលជារាងរាល់ថ្ងៃ
- ដាក់ទំលាប់ប្រចាំថ្ងៃឲ្យទៀងពេល
- ឲ្យកូនញាំអាហារពេលព្រឹកដែលមានសុខភាពល្អ
- មើលឲ្យកូនគេងឲ្យបានឆ្អែត

## បង្កើតទំនាក់ទំនងរវៀងផ្ទះនិងសាលា

- ជួបជាមួយគ្រូរបស់កូនដើម្បីឲ្យស្គាល់គ្នា
- ប្រាប់គ្រូអំពីអ្វីៗអំពីកូនឲ្យគ្រូដឹងដែលលោកអ្នកយល់ឃើញជាការសំខាន់
- ស្ម័គ្រចិត្តជួយនៅសាលា
- ចូលជាសមាជិកសមាគមមាតាបិតានិងគ្រូបង្រៀន PTA



## ចរិយាមាយាទដែលមានទំនួលខុសត្រូវ

កូនលោកអ្នកត្រូវបានរំពឹងថាឲ្យមានចរិយាមាយាទដែលមានទំនួលខុសត្រូវ។

### ដើម្បីបណ្តុះចរិយាមាយាទមានទំនួលខុសត្រូវ

- លើកទឹកចិត្តកូនឲ្យរៀនស្លៀកពាក់ខោអាវខ្លួនឯង
- លើកទឹកចិត្តកូនឲ្យរៀបចំទុកដាក់ប្រដាប់ប្រដារលេងពេលលេងរួច
- លើកទឹកចិត្តឲ្យកូនចេះចែកប្រដាប់ប្រដារលេងជាមួយក្មេងដ៏ទៃ
- លើកទឹកចិត្តកូនឲ្យចេះនិយាយបញ្ចេញអារម្មណ៏

## ភាពត្រឹមត្រូវនិងការចេះគោរពដល់អ្នកដ៏ទៃ

បង្កើតវិញ្ញាណនៃភាពត្រឹមត្រូវនិងចេះគោរពដល់អ្នកដ៏ទៃមានសារៈសំខាន់បំផុត។ នៅសាលា សិស្សត្រូវបានរំពឹងថាឲ្យចេះយោគយល់ចិត្តគ្នាទៅវិញទៅមក។

### ដើម្បីលើកទឹកចិត្តឲ្យមានភាពត្រឹមត្រូវនិងចេះគោរពដល់អ្នកដ៏ទៃ

- និយាយជាមួយកូនអំពីទឹកចិត្តរបស់អ្នកដ៏ទៃនិងការចេះយោគយល់គ្នា
- ផ្តល់ឱកាសសម្រាប់ឲ្យកូនលោកអ្នកជួយមិត្តភក្តិនៅពេលគេត្រូវការជំនួយ
- លើកទឹកចិត្តឲ្យកូនចេះរង់ចាំដល់វេនរបស់ខ្លួននៅពេលលេងជាមួយក្មេងដ៏ទៃ
- លើកទឹកចិត្តឲ្យកូនពិចារណាអំពីគំនិតយោបល់របស់គេ

## ការដោះស្រាយទំនាស់

សិស្សចូលសាលាមត្តេយ្យចាប់ផ្តើមចេះចចារ យោគយល់ ហើយស្វែងរកវិធីសហការគ្នាដើម្បីដោះស្រាយទំនាស់ជាមួយមិត្តភក្តិនិងមនុស្សពេញវ័យ។

### ដើម្បីបណ្តុះជំនាញចេះដោះស្រាយទំនាស់

- ជាមនុស្សចាស់ យើងធ្វើជាអ្នកសម្រួល កុំធ្វើជាអ្នកដោះស្រាយបញ្ហ
- លើកទឹកចិត្តកូនឲ្យនិយាយពន្យល់បញ្ហាឲ្យច្បាស់
- រំលឹកកូនលោកអ្នកអំពីភាពត្រឹមត្រូវហើយនិងអំពីវិន័យហើយនិងរបៀបរបប។



# ទំនួលខុសត្រូវផ្ទាល់ខ្លួន

## ក្លាយជាសមាជិកសហគមព្រើស្លួល (ភាពជាពលរដ្ឋ)

### ការចូលរួមប្រជាធិបតេយ្យ



វាជាការសំខាន់ណាស់ដែលកុមារចេះចូលរួមដោយមានទំនួលខុសត្រូវនៅក្នុងសកម្មភាពជាក្រុម។ វាជួយបណ្ដុះការយល់ដឹងអំពីការគិតសម្រេចចិត្តជាក្រុមហើយនិងការចេះគោរពដល់វិន័យភាគច្រើនហើយនិងគំនិតរបស់សមាជិកក្រុមដែលមិនយល់ស្របនឹងការសម្រេចភាគច្រើន។

**ដើម្បីលើកទឹកចិត្តនូវការចូលរួមប្រជាធិបតេយ្យ មាតាបិតាអាចៈ**

- បង្កើតទំលាប់ដែលដឹងពេលវេលាជាមុនដើម្បីឲ្យក្មេងរៀនពីការរំពឹងទុកហើយដឹងថាមានអ្វីនឹងកើតឡើងដោយពុំចាំបាច់រំលឹក។
- ពន្យល់មូលហេតុដែលគេបង្កើតច្បាប់(ឧ.ហេតុអ្វីបានជាការវាយអ្នកដ៏ទៃមិនអនុញ្ញាតឲ្យ)។
- ធ្វើគំរូអំពីចរិយាមាយាទដែលអ្នកចង់ឲ្យកូនមានដោយគោរពតាមវិន័យនិងហាត់ដោះស្រាយបញ្ហា។
- លើកទឹកចិត្តឲ្យកូនព្យាយាមដោះស្រាយបញ្ហាដោយខ្លួនឯង។
- លើកទឹកចិត្តហើយផ្ដល់ឱកាសឲ្យកូនលេងជាមួយក្រុមមិត្តភក្តិ។
- ប្រើពាក្យសម្រាប់បង្កើតវិន័យហើយពិភាក្សាអំពីវិន័យ

ក្មេងរៀនពីអ្វីដែលគេបានធ្វើហើយបានឃើញ។ វាជាការសំខាន់ណាស់សម្រាប់ក្មេងឃើញមនុស្សធំធ្វើគំរូអំពីចរិយាមាយាទមានទំនួលខុសត្រូវ ព្រមទាំងការផ្ដល់ឱកាសឲ្យក្មេងបង្ហាញភាពមានទំនួលខុសត្រូវផងដែរ។



### ធ្វើយ៉ាងណាកុំឲ្យមានការរំខានច្រើន

- បង្កើតកន្លែងនិងពេលវេលាសម្រាប់ធ្វើលំហាត់។
- ត្រៀមខ្លួនជួយប៉ុន្តែកុំធ្វើលំហាត់ឲ្យកូន។
- តាមដានពេលវេលាមើលទូរទស្សន៍ ប្រើកុំព្យូទ័រ និងលេខហ្គេម ព្រោះវាធ្វើឲ្យបាត់បង់ពេលវេលាច្រើន។

### អនុញ្ញាតឲ្យមានពេលវេលាសម្រាប់ធ្វើទំនាក់ទំនងជាមួយក្មេងដ៏ទៃ

- ផ្ដល់ឱកាសឲ្យកូនលេងកំសាន្តបន្ធូរអារម្មណ៍
- ដាក់កំរិតទៅលើសកម្មភាពក្រោយម៉ោងសាលា ដូចជាកីឡាឬធ្វើមេរៀន
- ដាក់ពេលឬថ្ងៃក្រៅម៉ោងសាលាសម្រាប់លេងជាមួយមិត្តភក្តិដើម្បីជួយស្ថាបនាមិត្តភាព។

### និយាយជាមួយកូនអំពីការរៀនសូត្រ

- និយាយជាមួយកូនអំពីសាលា។ ពេលកូនមកផ្ទះពីសាលា សួរសំណួរច្បាស់លាស់ ជាជាងគ្រាន់តែសួរថា“ថ្ងៃនេះនៅសាលាយ៉ាងម៉េចដែរ?” តែសួរថា “តើអ្វីមួយដែលល្អជាងគេដែលបានកើតឡើងនៅសាលាថ្ងៃនេះ?” ឬសួរថា “ប្រាប់ម៉ាក់ប៉ាអំពីអ្វីមួយដែលកូនបានរៀនចេះនៅសាលាមតេយ្យថ្ងៃនេះ”
- ដាក់បិតតាំងបង្ហាញនៅផ្ទះកិច្ចការដែលកូនបានធ្វើពីសាលា។
- លើកទឹកចិត្តឲ្យកូនខិតខំធ្វើកិច្ចការនៅពេលជួបប្រទះភាពលំបាកមុននឹងរកមនុស្សធំឲ្យជួយ។ ផ្ដោតទៅលើការសរសើរដល់ការព្យាយាម។
- បង្ហាញឲ្យកូនឃើញនូវទំនុកចិត្តរបស់លោកអ្នកទៅលើសមត្ថភាពរបស់កូន។

# ការលូតលាស់ផ្លូវចិត្តនិង ជំនាញធ្វើទំនាក់ទំនង



ភាពរួចរាល់សំរាប់សាលាមានឥទ្ធិពលជាខ្លាំងពីជំនាញផ្លូវចិត្តនិងទំនាក់ទំនង។ លើកទឹកចិត្តការលូតលាស់ផ្លូវចិត្តនិងការធ្វើទំនាក់ទំនងតាមរយៈធ្វើការទាក់ទងហើយនិងការលេងហើយជាគន្លិះដ៏សំខាន់សំរាប់ជោគជ័យទៅអនាគត។

## ការបណ្តុះបណ្តាលអត្តភាព

- រៀនដោះស្រាយបញ្ហាដោយណែនាំកូនឲ្យរកដំណោះស្រាយ
- លើកទឹកចិត្តទង្វើរល្អដោយទទួលដឹងលឺសរសើរលទ្ធផលទង្វើររបស់កូន
- ជួយកូនឲ្យចេះរបៀបគ្រប់គ្រងខ្លួនឯងដោយបង្កើតទម្លាប់ទៀងទាត់
- លេងល្បែងដែលមានវិន័យ
- កត់សម្គាល់អារម្មណ៏និងចរិយាមាយាទរបស់អត្តានិងរបស់អ្នកដ៏ទៃ
- ជួយកូនឲ្យចេះសម្រួលចិត្ត គំនិត និងអារម្មណ៏ឲ្យបានជាប់លាប់(ឧ. ការរំពឹងទុកជាមុននូវទម្លាប់ធ្វើអ្វីមួយដែលនឹងកើតមានឡើង សហការដោយមានការជួយរំលឹកតិចតួច ផ្តោតអារម្មណ៏ទៅលើកិច្ចការដែលកំពុងធ្វើហើយនិងចេះរបៀបផ្ទេរពីរកិច្ចការមួយទៅមួយ។

## ការធ្វើទំនាក់ទំនងជាមួយអ្នកដ៏ទៃ

ការធ្វើទំនាក់ទំនងជាមួយអ្នកដ៏ទៃផ្តល់ឱកាសឲ្យកូនលោកអ្នកបណ្តុះជំនាញសហការគ្នា រៀបគ្រោង ចាត់ចែង ចចារ និងរកដំណោះស្រាយ។

**ដើម្បីបណ្តុះទំនាក់ទំនងជាមួយអ្នកដ៏ទៃនិងមិត្តភាព:**

- ផ្តល់ឱកាសឲ្យកូនធ្វើទំនាក់ទំនងជាមួយមនុស្សពេញវ័យដែលកូនស្គាល់(ឧ. អាចារ្យ គ្រូបង្រៀនសាសនា អ្នកជិតខាង អ្នកលក់ទំនិញដែលធ្លាប់ស្គាល់)
- ផ្តល់ពេលវេលាឲ្យកូនលេងជាមួយក្រុមកុមារដែលមានគ្នា៣ទៅ៤នាក់
- ផ្តល់ឱកាសឲ្យកូនចូលរួមក្នុងថ្នាក់ផ្សេងៗ ដូចជាភ្លេង កីឡា រាំ ជាដើម។
- រៀបគ្រោងពេលវេលាសម្រាប់លោកអ្នកទុកកូនជាមួយមនុស្សពេញវ័យដែលទុកចិត្ត។ ធ្វើយ៉ាងនេះគឺផ្តល់ឲ្យកូននូវឱកាសឲ្យមានទំនុកចិត្តដោយដឹងថាលោកអ្នកនឹងវិលត្រឡប់មកយកគេវិញជានិច្ច។
- រៀបចំពេលវេលាសម្រាប់មិត្តភាពដោយអនុញ្ញាតឲ្យកូនលេងល្បែងដែលមានភាពស្មុគស្មាញ។ ទំនាស់អាចកើតមានឡើង ប៉ុន្តែវានឹងអនុញ្ញាតឲ្យកូនចេះធ្វើការចចារនិងដោះស្រាយបញ្ហា។
- ផ្តល់ឱកាសឲ្យកូនចូលរួមនៅក្នុងសកម្មភាពជាក្រុមធំដែលមានមនុស្សពេញវ័យម្នាក់ជាអ្នកប្រាប់ណែនាំឲ្យធ្វើសកម្មភាព។

